CITY OF LONGBEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី ១៧ ខែមិថុនាឆ្នាំ ២០២០
ទំនាក់ទំនង៖ មជ្ឈមណ្ឌលព័ត៌មានរួមនៃទីក្រុងឡុងប៊ិច 562.570.NEWS(6397) jic@longbeach.gov

សម្រាប់សេចក្តីប្រកាសជាបន្ទាន់

# ទីក្រុងឡុងប៊ិចនឹងចាប់ផ្តើមកម្មវិធីបើកចំហរផ្លូវ

*ផ្លូវថ្នល់នឹងត្រូវបិទមិនឱ្យយានយន្តចេញចូលដើម្បីអនុញ្ញាតឱ្យមានការបរិភោគអាហារឬការលេងនៅខាងក្រៅ*

ទីក្រុងឡុងប៊ិច,រដ្ឋកាលីហ្វ័រញ៉ា - នៅប៉ុន្មានសប្តាហ៍ខាងមុខនេះទីក្រុងឡុងប៊ិចនឹងផ្តួចផ្តើមកម្មវិធីបើកចំហរផ្លូវថ្មី។ កម្មវិធីនេះនឹងដាក់កំណត់លើចរាចរណ៍ឆ្លងកាត់តាមដងផ្លូវនានាទូទាំងទីក្រុងនិងធ្វើឱ្យតំបន់ទាំងនេះខ្លាយជាកន្លែងធ្វើដំណើរយ៉ាងសកម្មសម្រាប់សកម្មភាពដូចជាការដើរការជិះកង់និងរទេះរុញ។

លោកអភិបាលក្រុង Robert Garcia បានមានប្រសាសន៍ថា "ឡុងប៊ិចកំពុងបើកសេដ្ឋកិច្ចរបស់យើងឡើងវិញហើយយើងប្តេជ្ញាជួយអាជីវកម្មបើកដំណើរការឡើងវិញដោយសុវត្ថិភាពដោយផ្តល់កន្លែងទំនេរបន្ថែមនៅខាងក្រៅ។"

ការបង្កើតគំនិតផ្តួចផ្តើមបើកចំហផ្លូវថ្នល់និងស្វែងរកវិធីដើម្បីបើកទីធ្លាសាធារណៈបន្ថែមទៀតនៅទូទាំងទីក្រុងអនុញ្ញាតឱ្យបង្កើនសកម្មភាពខាងក្រៅខណៈពេលដែលរក្សាចម្ងាយរាងកាយពីគ្នាដែលសមស្របតាមបទបញ្ជាសុខភាពបច្ចុប្បន្ន។ ការបិទផ្លូវថ្នល់ពាណិជ្ជកម្មផ្តល់ឱកាសឱ្យមានសកម្មភាពអាជីវកម្មនៅខាងក្រៅដូចជាការបរិភោគអាហារដើម្បីជំរុញឱ្យសេដ្ឋកិច្ចងើបឡើងវិញ។ ការបិទផ្លូវក៏ផ្តោតលើនិរន្តរភាពប្រសិទ្ធភាពនិងគំរូមធ្យោបាយដឹកជញ្ជូនដទៃទៀតដែលមានគោលបំណងកាត់បន្ថយឬលុបបំបាត់

ការបំពុលបរិស្ថានខណៈពេលដែលផ្តល់អាទិភាពនិងលើកកម្ពស់ឱកាសរស់នៅប្រកបដោយសុខភាពល្អ។

មន្ទីរសាធារណការ (PW) បានធ្វើការជាមួយការិយាល័យក្រុមប្រឹក្សាក្រុងនិងសង្កាត់អាជីវកម្មដើម្បីកំណត់ផ្លូវថ្នល់សង្កាត់សំខាន់ៗនៅទូទាំងទីក្រុងដើម្បីគាំទ្រដល់កិច្ចប្រឹងប្រែងនេះ។ ផ្លូវថ្នល់នឹងត្រូវបិទជារៀងរាល់ថ្ងៃចាប់ពីម៉ោង ៩ ព្រឹកដល់ម៉ោង ៥ ល្ងាច។ ប្រជាជនឬអ្នកជំនួញដែលចាប់អារម្មណ៍នឹងទីតាំងដែលមានទីតាំងនៅតាមដងផ្លូវដែលបើកចំហនៅក្នុងតំបន់របស់ពួកគាត់អាចចូលទៅកាន់គេហទំព័រ longbeach.gov/GoActiveLB សម្រាប់ព័ត៌មានបន្ថែម។

វិស្វករចរាចរណ៍ក្រុងបានវាយតម្លៃទីតាំងផ្លូវបើកចំហរដែលបានស្នើសុំសម្រាប់ភាពសមរម្យនិងសុវត្ថិភាព។ នឹងមានការវាយតម្លៃបន្តបនាប់ទៅលើដងផ្លូវដែលត្រូវបានអនុម័តឱ្យបិទក្នុងរយៈពេលនៃកម្មវិធីនេះដើម្បីធានាសុវត្ថិភាពដល់អ្នកប្រើប្រាស់ទាំងអស់។ បុគ្គលិកនៃមន្ទីរសាធារណការនឹងធ្វើការជាមួយប្រជាជននិងអាជីវកម្មជាប្រចាំដើម្បីគូសបញ្ជាក់សកម្មភាពដែលបានអនុម័តនិងដោះស្រាយកង្វល់នានា។ ស្លាកសញ្ញានឹងត្រូវតំឡើងនៅទីតាំងនីមួយៗដែលនឹងមានព័ត៌មានទាក់ទងនឹងសកម្មភាពដែលបានអនុម័តនិងការចូលប្រើដែលមានកំណត់។

កម្មវិធីនេះនឹងមិនប៉ះពាល់ដល់ការដែលអ្នករស់នៅក្នុងក្រុងអាចចូលទៅកាន់សង្កាត់បានឡើយ។ ការបិទផ្លូវគឺរំពឹងថានឹងបន្តរហូតដល់ថ្ងៃទី ៣១ ខែតុលាឆ្នាំ ២០២០ ។

**អំពីទីក្រុងឡុងប៊ិច**

ជាទីលំនៅដ្ឋាននៃប្រជាជនប្រមាណ ៤៨០,០០០ នាក់ទីក្រុងឡុងប៊ិចបានទទួលពានរង្វាន់និងជាទីក្រុងច្នៃប្រឌិតដេលផ្តល់ជូននូវភាពសំបូរបែបនៃពិភពលោកខណៈពេលដែលរក្សាលក្ខណៈបុគ្គលនិងដេលបង្កើតឡើងពីសង្កាត់ផ្សេងៗពីគ្នាដែលបានផ្តុំនៅតាមបណ្តោយឆ្នេរសមុទ្រប៉ាស៊ីហ្វិក។ ក្នុងនាមជាទីក្រុងដែលមានសេវាកម្មពេញលេញទីក្រុងឡុងប៊ិចជាលំនៅដ្ឋានរបស់នាវា Queen Mary, អាងចិញ្ចឹមត្រីនៃមហាសមុទ្រប៉ាស៊ីហ្វិក (Aquarium of the Pacific), សារមន្ទីរនិងរោងកុនជាច្រើន, សាលារៀនដែលត្រូវបានវាយតម្លៃខ្ពស់, អាកាសយានដ្ឋានឡុងប៊ិច, កំពង់ផែឡុងប៊ិច ក៏ដូចជាមន្ទីរផ្សេងៗដែលបានទទួលពានរង្វាន់ជាច្រើនដូចជាមន្ទីរសុខាភិបាល មន្ទីរឧទ្យានការកំសាន្តនិងសមុទ្រ មន្ទីរសេវាកម្មអភិវឌ្ឍន៍ និងមន្ទីរផ្សេងៗទៀត។ ទីក្រុងនេះក៏មានសាកលវិទ្យាល័យនិងមហាវិទ្យាល័យដែលត្រូវបាន

ការគោរពខ្ពស់ ក៏ដូចជាកន្លែងចិញ្ចឹមសត្វជាប្រវត្តិសាស្ត្រចំនួន២ មន្ទីរពេទ្យ៥ ទីតាំង៥សម្រាប់លេង ហ្គោល សួន១៧០ ឆ្នេរសមុទ្រជាច្រើនម៉ាយល៍ម៉ា ផ្លូវសម្រាប់ជិះកង់ និងកម្មវិធីជិះកង់ដែលមានការ ចែករំលែក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីក្រុងឡុងប៊ិចសូមចូលទៅកាន់គេហទំព័រ http://longbeach.gov/។ សូម តាមដានទីក្រុងឡុងប៊ិចនៅលើបណ្តាញសង្គមសម្រាប់ព័ត៌មានថ្មីៗនៅលើ ហ្វេសប៊ុក ធ្វីតធ័ រ Instagram និង យូធូប។

សម្រាប់ព័ត៌មានថ្មីៗអំពីជំងឺ COVID-19 រួមទាំងព័ត៌មានលម្អិតអំពីអ្វីដែលទីក្រុងឡុងប៊ិចកំពុងអនុវត្ត ដើម្បីការពារសុវត្ថិភាពដល់ប្រជាជនសូមមេត្តាចូលទៅកាន់គេហទំព័រ longbeach.gov/COVID19 ហើយតាមដាន @LongBeachCity នៅលើបណ្តាញសង្គមហ្វេសប៊ុក ធ្វីតធ័រ និង Instagram។

# # #